# ទស្សនវិជ្ជាសាសនា : សក្តានុពលនៃជំនឿសាសនាខ្មែរ

( Philosophy of Religion: The Potential of Khmer Religious Beliefs )

ដោយ : បណ្ឌិត **ឆ្កាន់ ធុល**

មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

រាជបណ្ឌិត្យសភាកម្ពុជា

## ១- សេចក្តីផ្តើម

ចិត្ត (mind) គឺជាអង្គវត្ថុមួយដែលមានតែឈ្មោះគ្មានរូប ហើយមានតែនៅក្នុងមនុស្សប៉ុណ្ណោះ។ ចិត្តមិនមាននៅទី ណាក្រៅពីនៅក្នុងខ្លួនមនុស្សនោះឡើយ។ **ចិត្ត** ជាគូនឹង **កាយ** (body/matter) ដែល តែង តែមា នអន្តរកម្មជាមួយគ្នាដោយទៀងទាត់។ មនុស្សខ្លះឱ្យតម្លៃលើ**កាយ** (រូបធាតុ/សម្ភារៈ) សំខាន់ជាងចិត្ត (អរូប ធាតុ) ដែលផ្ទុយទៅនឹងមនុស្សខ្លះឱ្យតម្លៃ **ចិត្ត** សំខាន់ជាង **កាយ** ទៅតាមការយល់ដឹងហេតុផលនិងបទពិសោធន៍រៀងៗខ្លួន របស់ពួកគេ។ តាមបទពិសោធន៍ **ចិត្ត** មានសក្តានុពលធំធេង និងមានឥទ្ធិពលខ្លាំងទៅលើ **កាយ**។ ចំណែកឯ **កាយ** មិនថាតែមនុស្សទេ សត្វណា ក៏មានវាដែរ។ វាមានសក្តានុពលនិងឥទ្ធិពលតិចតួចទៅលើ**ចិត្ត**។ ដោយសារសក្តានុពលនិងឥទ្ធិពល **ចិត្ត** បានប្រែក្លាយ **សត្វមួយប្រភេទ** នៅក្នុងចំណោមប្រភេទសត្វនានាក្លាយជា **សត្វសនិទាន** (rational animal) ដែលគេអាចហៅដោយខ្លីថា **មនុស្ស** (human being) នេះឯង។ **មនុស្ស** គឺជាសត្វដែល**ចេះគិត** (reasoning), **ចេះមានអារម្មណ៍** (feeling) ហើយនិង**ចេះប្រព្រឹត្តអំពើដោយចេតនា** (intentional act) ដែលនាំឱ្យគេចាត់ចូលទៅក្នុងប្រភេទសត្វថ្នាក់ខ្ពស់លើសត្វដទៃៗទៀត។ នៅក្នុងសកម្មភាពប្រចាំថ្ងៃ **មនុស្ស** ស្គាល់ខុសត្រូវ មានមនសិការ ទទួលខុសត្រូវ (សត្វសីលធម៌), ចេះធ្វើនយោបាយ(សត្វនយោបាយ), ចេះបង្កើតសិល្បៈនិងចេះសប្បាយនឹងវា(សត្វ សោភ័ណ), ចេះបង្កើតផលិតផល (សត្វ ផលិត ផល) និងជាពិសេស **មនុស្ស** ចេះ បង្កើត **ជំនឿសាសនា** ដែលមាន **ជំនឿលើព្រះបង្កើតលោក** ជាធាតុចម្បងនៅ ក្នុងនោះ។ តើអ្វីជា **ជំនឿសាសនា**?

## ២ - ន័យនៃបញ្ញត្តិមួយចំនួន និងន័យនៃប្រធានបទ

ប្រធានបទដែលខ្ញុំលើកយកមកចោទនិងធ្វើការស្រាវជ្រាវនៅពេលនេះ មានចំណងជើងថា "**សក្តានុពលនៃជំនឿសាសនា**"។ តើវាមានន័យដូចម្តេច? អ្វីជា **សក្តានុពល? អ្វីជា**

***ជំនឿ? និងអ្វីជាសាសនា? អ្វីជាសក្តានុពលនៃជំនឿសាសនា?***

*នៅក្នុងអត្ថបទមុនៗដែលមិត្តអ្នកអានធ្លាប់បានអានរួចមកហើយនោះគឺ អត្ថបទស្តីពី "**ជំនឿខ្មែរ** និងអត្ថបទស្តីពី "**អត្ថន័យសាសនា**"។ ឥឡូវនេះ និងនៅពេលនេះ ខ្ញុំធ្វើការសិក្សាស្រាវជ្រាវពី **ជំនឿ** និង **សាសនា** មួយផ្នែកទៀតដែលផ្តោតជាសំខាន់ទៅលើ "**សក្តានុពល**" របស់ពួកវា។*

***ជំនឿសាសនា*** *គឺជាបន្សំពាក្យពីរដែលមានន័យជ្រៅទាក់ទងទៅនឹង**បញ្ហាចិត្តសាស្ត្រ*** (Psychological issues) *ដែលអាចឱ្យយើងនិយាយបានថា **សាសនា** គឺជាចំណីស្មារតីរបស់មនុស្ស ដែលពួកគេតែងត្រូវការជាប្រចាំ មិនអាចខ្វះបាន មិនថាយប់ឬថ្ងៃសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ យើងអាចនិយាយបានថា ទីណាមានមនុស្សរស់នៅទីនោះក៏ត្រូវបានគេគិតផងដែរថាក៏មានសាសនាដែរ។ **សាសនា** និង **ជីវិតមនុស្ស** តែងប្រព្រឹត្តទៅជាមួយគ្នាជាដរាប មិនខុសអ្វីពី **សង្គម** និង **នយោបាយ** ដែលតែងត្រូវការគ្នាជាដរាបនោះឡើយ។ ហេតុនេះ **ជំនឿសាសនា** មាន **សក្តានុពលដ៏ធំធេង** ចំពោះជីវិតរស់នៅរបស់មនុស្ស។*

***សក្តានុពល*** (potential) *ន័យទី១ និយាយពី **លទ្ធភាព*** (possibility) *ដែលអាចធ្វើឱ្យអ្វីមួយកើតឡើងបាន ឬអាចឱ្យគេអភិវឌ្ឍអ្វីមួយបាន។ ឧទាហរណ៍ ខេត្តក្រចេះមានសក្តានុពលខាងវិស័យអេកូទេសចរណ៍។ ខ្ញុំទទួលស្គាល់ពីសក្តានុពលរបស់យុវជនខ្មែរនៅក្នុងចលនាអភិវឌ្ឍសង្គមជាតិ។ ន័យទី២និយាយពី **គុណភាព*** (qualities) *ដែលមានអត្ថិភាព ហើយដែលអាចឱ្យគេ អភិវឌ្ឍបាន។ ឧទាហរណ៍ សូមប្អូនៗ និស្សិតទស្សនវិជ្ជាស្វែងរកបំពេញសក្តានុពលរបស់ខ្លួន។ នាងបុស្បាមានសក្តានុពលខាងសិល្បៈ ឬមានសក្តានុពលជា សិល្បៈការិនី។ **សក្តានុពលភាព*** (potentiality) *និយាយពី **អំណាច*** (power) *ឬ **គុណភាព*** (quality) *ដែលមានអត្ថិភាព ប៉ុន្តែ នៅមិនទាន់ត្រូវបានគេអភិវឌ្ឍនៅឡើយទេ។ ឧទាហរណ៍ សក្តានុពលភាពរបស់មនុស្សវ័យជំទង់នៅមិនទាន់ត្រូវបានគេប្រើប្រាស់ដោយពេញលេញនៅឡើយទេ*[១]*។*

***ជំនឿសាសនា*** > *ជំនឿ+សាសនា។ "**ជំនឿ*** (faith = trust/confidence)*" ការជឿ ជាក់ ឬការមានទំនុកចិត្តខ្លាំងទៅលើអ្វីមួយ ឬ*

---

[១] *Jonathan* Crowther, *Oxford Advanced Learner's Dictionary of Current English,* Oxford University Press, Oxford New York, 5th Ed, 1995, p 902

នរណាម្នាក់។ បើនៅក្នុងបរិបទសាសនា វាគឺជាការជឿមាំលើព្រះ។ "ជំនឿ (belief = the feeling of being certain)" ការមានវេទនារម្មណ៍ប្រាកដថាអ្វីមួយ មានអត្ថិភាព ឬមានពិត[២]។

ឯពាក្យថា "**សាសនា** (religion)" មានន័យខុសៗគ្នាទៅតាមមនុស្សដែល ធ្លាប់មានបទពិសោធន៍។ សាសនាគឺជាពាក្យដែលគេប្រើក្លាយមកពីពាក្យថា "សាសន" ដែលមានន័យថា ពាក្យបណ្តាំ , ពាក្យផ្តាំផ្ញើ; ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ; សាសនា, លទ្ធិ; ពាក្យបង្គាប់, ការបង្គាប់បញ្ជា ; ដំណឹង; សំបុត្រ; ពាក្យប្រកាស, ការប្រកាសប្រាប់; ការជឿស្តាប់; ការដាក់ទណ្ឌកម្ម, ការផ្ចាលទោស; ការកែសម្រួល ; ការគ្រប់គ្រង; ការត្រួតត្រា[៣]។ ឧទាហរណ៍ សាសនាព្រះពុទ្ធ, សាសនាព្រាហ្មណ៍, ឥស្លាមសាសនា, គ្រិស្តសាសនា។ សាសនាតាមន័យស័ព្ទអង់គ្លេស "religion" មានន័យពីរបែបៈ ន័យទី១ គឺជាជំនឿទៅលើអត្ថិភាពរបស់ **អាទិទេព** (god) ឬ**ទេវ្តា** (gods) ជាពិសេសជំនឿ ដែលថា អាទិទេព ឬទេវ្តាទាំងនោះបានបង្កើត **សាកលលោក** (the universe) ហើយនិងផ្តល់ឱ្យ **មនុស្ស** (human beings) នូវ **ធម្មជាតិផ្លូវចិត្ត ឬវិញ្ញាណ** (spiritual nature) ដែលបន្តឱ្យមានអត្ថិភាពបន្ទាប់ពីរលត់រាងកាយទៅ។ ន័យទី២ សាសនា សំដៅយកប្រព័ន្ធជំនឿក្នុងការគោរព បូជាដោយឡែកមួយ ដែលពឹងផ្អែកទៅលើ **ជំនឿសាសនា** (religious belief)៖ សាសនាគ្រីស្ត/សាសនាជ្វីវ (Jewish)/ សាសនាហិណ្ឌូ[៤]។ដូច្នេះ**ជំនឿសាសនា**គឺជា**ជំនឿអរូបី** ដែលឋិតក្រៅខ្លួនមនុស្ស ពោលគឺ**ជំនឿលើព្រះ** ឬ **ភាវៈអធិធម្មជាតិ** (superna-tural being) ហើយនិង **ព្រលឹង** (spiritual)។

ហេតុនេះន័យរួមរបស់ប្រធានបទ "**សក្តានុពលនៃជំនឿសាសនា**" គឺផ្តោតការសិក្សាស្រាវជ្រាវជាសំខាន់ទៅលើ **លទ្ធភាពនៃជំនឿសាសនា ដែលអាចជួយឱ្យមនុស្សមានសេចក្តីស្ងប់, មានលំនឹងផ្លូវ ចិត្ត, និងមានវិបុលភាពខាងរាងកាយ** (សុខទាំងកាយសប្បាយទាំងចិត្ត)។ តើ កត្តាអ្វីខ្លះដែលជំរុញឱ្យមនុស្សចាប់ផ្តើម ជំនឿសាសនាដំបូងរបស់ពួកគេឡើង?

## ៣- ការចាប់ផ្តើមជំនឿសាសនាដំបូង

**ជំនឿសាសនា** ឥតកើតដំណាលគ្នានឹងកំណើតមនុស្សនោះទេ ពីព្រោះនៅក្នុងរបបកុម្មុយនិស្តបុព្វកាល គឺនៅពេលដែលមនុស្សមិនទាន់ចេះធ្វើទស្សនវិជ្ជា

---

[២] Cambridge Advanced Learner's Dictionary, 3rd ed. p faith, p belief

[៣] ជួនណាត, វចនានុក្រមខ្មែរអេឡិចត្រូនិច, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធ សាសនបណ្ឌិត្យ, ២០០៨, ទំព័រ សាសន

[៤] *Jonathan Crowt*her, op. cit., p 988

(philosophize) មានន័យថា នៅពេលដែលមនុស្សមិនទាន់ចេះឆ្ងល់ មិនទាន់ចេះគិតនៅឡើយនោះ នៅពេលនោះពួកគេនៅមិនទាន់មាន **ជំនឿសាសនា** នៅឡើយទេ។ ទើបមកដល់ចុងរបបនេះ គឺនៅពេលដែល **ពន្ធកទស្សនវិជ្ជា** ចាប់ផ្តើមដុះឡើង គឺវាស្តែងឡើងនៅក្នុង **ជំនឿទេវកថា** (theology), **ជំនឿតូតឹមនិយម**[៥] (totemism), និង **ជំនឿវិញ្ញាណនិយម** (animism)។ ជំនឿទាំងនេះគឺជារូបរាងពិតនៃ **ជំនឿសាសនា**។ ហេតុនេះគេអាចនិយាយបានថា **ពន្ធកទស្សនវិជ្ជា** បានចាប់ផ្តើមនៅក្នុង **ជំនឿសាសនា**។ **ជំនឿសាសនា** បានបន្តអភិវឌ្ឍទៅតាមដំណើររីកចម្រើនរបស់ទស្សនវិជ្ជា។

នៅក្នុងការដោះស្រាយចម្ងល់ថាតើសាសនាកើតឡើងយ៉ាងដូចម្តេចនោះ គឺជាចំណោទមួយដែលតែងតែចោទសួរ ជាញឹកញយ ទាំងអ្នកមានគំនិតសាមញ្ញ ទាំងបញ្ញវន្តដែលចាប់អារម្មណ៍ ទៅលើវិធីផ្សេងដែលសាសនាបានជះឥទ្ធិពលទៅលើការគិត និងវិធីផ្សេងៗរបស់បុគ្គលម្នាក់ៗ ឬក្រុមៗ ស្ទើរជាច្រើនបានចាប់ផ្តើមពីឫសគល់សាសនា រហូតដល់កត្តាមួយចំនួនដែលគេអាចធ្វើចំណាត់ថ្នាក់ទៅជា២ ប្រភេទធំៗ គឺ៖ **កត្តាមនុស្ស** (human) និង **កត្តាចក្រវាឡ** (cosmic)។ ប្រភេទទី១ ទាក់ទងដល់ **ធម្មជាតិមនុស្ស** (the nature of man) ជាពិសេស **សមាសភាពចិត្តសាស្ត្រ** (psychological makeup) របស់គេ។ ប្រភេទទី២ ទាក់ទងទៅនឹង **ធម្មជាតិពិភពលោក** (the nature of the world) ដែលមនុស្សរស់នៅៗក្នុងនោះ។ ការពិភាក្សាពីប្រភេទនីមួយៗ ប្រព្រឹត្តទៅទៅតាមលំដាប់លំដោយដូចខាងក្រោម៖

មានមនុស្សជាច្រើនដែលតាមដានពីការចាប់ផ្តើមរបស់សាសនាចំពោះ "វេទនារម្មណ៍ ដែលមិនអាចពន្យល់បានអំពី **ពិសិដ្ឋភាព** (the holy)" ហើយនិង "ការវាយតម្លៃពីអ្វីមួយថាជា **ភាពសក្តិសិទ្ធិឬពិសិដ្ឋភាព** (sacred)" ដែលមនុស្សសម័យដើមនិយាយប្រាប់ពីការដែលពួកគាត់ធ្លាប់មានបទពិសោធន៍ជាមួយ។ ពួកគេចាត់ទុក **វេទនាអារម្មណ៍** និង **វត្ថុស័ក្តិសិទ្ធិ** បែបនេះថាជាការបង្ហាញពី **អត្ថិភាព នៃភាវៈអាថ៌កំបាំង** (invisible Being) ដែល **អំណាចគ្មានព្រំដែន** (limitless powers) របស់ភាវៈនេះអាចបង្កឱ្យពួកគេសុខ និងមានគ្រោះថ្នាក់បានដោយផ្អែកទៅលើ ទំនាក់ទំនងរបស់ពួកគេជាមួយភាវៈនេះ។ ដើម្បីសុំការអនុគ្រោះដូចជាការការពារ, ការប្រមូលភោគផលបានល្អ, ឬការយក ឈ្នះក្នុងសមរភូមិ មនុស្សត្រូវតែគោរព និងសែនព្រេនដល់ **ភាវៈពិសិដ្ឋ** និង **មាន ឫទ្ធានុភាព** នេះ។ **វត្ថុស័ក្តិសិទ្ធិ** (Sacred objects) ដែលគេចាត់ទុកថា ជា

---

[៥] ឆយ ឃីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ ៤

តំណាង នៃភាវៈនេះត្រូវគេរៀបចំទុកឱ្យនៅដោយឡែកពីមនុស្ស ហើយថែរក្សាមិនឱ្យប្រឡាក់ប្រឡូសជាមួយនឹង **វត្ថុមិនពិសិដ្ឋ** (unholy things) ដោយគិតរួមទាំងខ្លួនឯងផងដែរ។ មនុស្សសម័យបុព្វកាល ថាតើពួកគេមានលទ្ធភាពអាចបែងចែកវត្ថុមួយចំនួនថា ជាវត្ថុស័ក្តិសិទ្ធិដូចម្តេចនោះ គឺពិបាកនឹងកំណត់បានណាស់។ វាអាចទៅរួចដូចដែលទស្សនវិទូនានាបានបង្កើតទ្រឹស្តីថា វាគឺជា**លទ្ធផលនៃបទពិសោធន៍** របស់មនុស្សដែលទៅហួសពីការគ្រប់គ្រង និង ការយល់ដឹងរបស់គេបាន។ បើតាម លោក **ហូវ** (Houf) យល់ថា៖ "បើតាមគំនិតទូលំទូលាយចំពោះវត្ថុពិសិដ្ឋ ការចាប់ផ្តើមសាសនាដំបូងមកពីការមានវេទនារម្មណ៍ថា **វត្ថុនានា** មានលក្ខណៈ **អាថ៌កំបាំង** (mysterious), **ស័ក្តិសិទ្ធិ** (sacred) និងមាន **ឫទ្ធានុភាព** (powerful) ហើយនិងមានសារៈសំខាន់យ៉ាងចាំបាច់ចំពោះ **សុខុមាលភាពរបស់មនុស្ស** (human welfare) ដែលទាមទារឱ្យគេយកចិត្តទុកដាក់ និងពិនិត្យពិច័យឱ្យបានហ្មត់ចត់។ ការមាន **វេទនារម្មណ៍អំពីស័ក្តិសិទ្ធិ** នេះបានរីកលូតលាស់ដោយសារតែកត្តា ខាងក្រៅទៅលើបុគ្គលម្នាក់ៗ ប៉ុន្តែវាបានជិតជាប់នៅក្នុងគំនិត និងការរំភើបចិត្ត (emotions) យ៉ាងមានឫទ្ធានុភាព ហើយ ជះឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើ **ជីវិត**"[៦]។

ផ្តើមចេញពីទស្សនៈវិស័យខុសគ្នា សាសនាត្រូវបានប្រព្រឹត្តទៅតាម **បំណងប្រាថ្នា** របស់មនុស្សដើម្បីរស់នៅ ឬ **តម្រូវការ** (desire) ដើម្បីឱ្យជីវិតរស់នៅមួយ ពេញលេញ និងគ្រប់គ្រាន់។ សាសនាត្រូវ បានគេទទួលយកធ្វើជាមធ្យោបាយមួយដែលតាមរយៈមធ្យោបាយនេះ មនុស្សអាចសម្របខ្លួនទៅក្នុងពិភពលោកដែលគេរស់នៅៗក្នុងនោះបាន ហើយវាជាដំណើរការបទពិសោធន៍បំពេញចិត្តមួយ ហើយនិងជីវិតមានន័យមួយ។ សាសនាក៏បានរីកចម្រើនផងដែរ ដោយសារតែការរលឹកដឹងរបស់មនុស្ស ហើយនិងការទទួលស្គាល់ពិភពដ៏ល្អវិសេសមួយ ដែលផ្តល់ខ្លឹមសារនិងសារៈសំខាន់ចំពោះជីវិតរបស់គេ។ សាសនាគឺជាការឆ្លើយតបរបស់មនុស្សចំពោះវត្ថុមាននៃពិភពអាថ៌កំបាំង (an unseen world) ដែលនាំឱ្យគេស្ញើចសរសើរ គោរពនិងជឿជាក់។

ហេតុដែលនាំឱ្យមនុស្សមានលក្ខណៈសាសនា ត្រូវបានបញ្ជាក់គុណសម្បត្តិគ្រប់គ្រាន់ដាច់ដោយឡែកចំពោះ ធាតុជាក់លាក់នានាដែលមាននៅក្នុង **សមាសធាតុចិត្តវិទ្យា** (psychological composition) របស់គេ។ ធាតុទាំងនេះមានដូចជា **ទំនោរសភាវគតិ** (instinctive tendency) ឬ **ទំនោរធម្មជាតិ** (natural tendency) ដែលគេចាត់ទុកថាជាផ្នែកមូលដ្ឋាននៃធម្មជាតិ

[៦] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974, p 146

របស់មនុស្ស ហើយ និងបង្កើតជាមូលដ្ឋាន ត្រៀមមួយសម្រាប់អភិវឌ្ឍន៍សាសនានៅក្នុង បុគ្គលម្នាក់ៗ។ **ធាតុចិត្តសាស្ត្រ** ទាំងនេះមាន ដូចជា **ការភ័យខ្លាច** (fear), **ការកោតស្ញប់ស្ញែង** (awe), **គរុការភាព** (reverence ការបង្អោនខ្លួនគោរព), **សេចក្តីស្រឡាញ់** (love) នៅគ្រប់ទម្រង់របស់វា, **ភាពជាក្រុម** (gregariousness) ឬ **សង្គមីយភាព**(sociability), **ការចង់ដឹងចង់ឃើញ** (curiosity), **ការ ស្តាប់បង្គាប់** (submissiveness) ក៏ដូចជា **សេចក្តីអះអាង**(assertiveness) ជាដើម។ ធាតុបីដំបូងគឺ **ការភ័យខ្លាច**,**ការកោតស្ញប់ស្ញែង** និង **គរុការភាព** ត្រូវបានគេចាត់ទុកថាជាធាតុសំខាន់ជាងគេក្នុងចំណោមធាតុទាំងប្រាំបីខាងលើ។**ការភ័យខ្លាច**(fear) គឺជា **វេទនារម្មណ៍មូលដ្ឋាន** ហើយនិងជាធាតុមូលដ្ឋានមួយទៅលើ**ការកោតស្ញប់ស្ញែង**(awe) ដែលវេទនារម្មណ៍សាសនា (religious feelings) ចាប់ផ្តើមកើតឡើង។ **ការកោតស្ញប់ស្ញែង** បណ្តាលឱ្យមានវេទនារម្មណ៍អំពី **គរុការភាព** ដែលត្រូវបានគេជឿថាជា "សញ្ញាសម្គាល់ សាសនា (hallmark of religion)"[៧]។

មានកត្តាដទៃៗទៀតដែលជះឥទ្ធិពលមកលើមនុស្ស ដើម្បីឱ្យបានទៅជា សាសនា គឺ **ពិភពធម្មជាតិ** (the natural world) ដែលគេកំពុងរស់នៅៗក្នុងនោះ។ ពិភពលោករបស់យើងមានលក្ខណៈ **អស្ចារ្យ** និង **អាថ៌កំបាំង** ពេកណាស់ ដែលគ្រប់សម័យកាល ចាប់តាំងពីសម័យបុព្វ កាលរហូតមកដល់សម័យទំនើប មនុស្ស មានការងឿងឆ្ងល់, ច្របូកច្របល់, និង មានបញ្ហា ដោយសារតែការកើតឡើងនៅក្នុងពិភពលោកនេះ មិនអាចឱ្យគេទស្សន៍ទាយ, គ្រប់គ្រង, ឬពន្យល់បាន។ មនុស្សអសមត្ថភាព, ការទាល់ប្រាជ្ញា (baffled), ភាពច្របូកច្របល់នៅក្នុងចិត្ត (confused) ហើយនិងការមានបញ្ហាដោយសារតែការ កើតឡើងក្នុងលោកនេះ មិនមានលទ្ធភាព ព្យាករណ៍, គ្រប់គ្រង ឬ ពន្យល់ បាន។ **គ្រោះមហន្តរាយធម្មជាតិ** (natural calamities) ដូចជា គ្រោះរាំងស្ងួត (drought) , គ្រោះទុរភិក្ស (famine), ឬឧបទ្រព ចង្រៃ (pestilence) និង សោកនាដកម្ម (tragedy) ផ្ទាល់ខ្លួនដូច ជាការយកឈ្នះលើខ្លួនឯង (personal defeat), ភាពអាម៉ាស់ (humilia-tion) និងសេចក្តីស្លាប់ (death) សុទ្ធតែជាឧទាហរណ៍អំពីបាតុភូតគួរឱ្យកោតខ្លាចធម្មជាតិ។ បើទោះជាមានការរីកចម្រើនយ៉ាងខ្លាំងក្លា ខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចប្រៀបផ្ទឹមទៅនឹង **ភាពមិនអាចទាយទុក បាន** (unpredictableness), **អាថ៌កំបាំង** (mystery) ហើយនិង **ភាពអស្ចារ្យ** របស់ពិភពធម្មជាតិនោះដែរ។ ដោយឈរលើមូលហេតុបែបនេះហើយទើបបានជាមនុស្សនាំគ្នាបង្កើតជំនឿមួយ ថា មាន **ភាវៈអធិធម្មជាតិ** (supernatural Being) មួយ ដែលបង្កឱ្យវត្ថុទាំងនេះកើតមានឡើង ហើយគោលបំណង

[៧] Venancio B. Ardales, op. cit., p 146

របស់ភាវៈអធិធម្មជាតិនោះ មនុស្សមិនគួរឆ្ងល់ ឬមានសង្ស័យយល់ដឹងដោយពេញលេញនោះបានទេ។ ជំនឿបែបនេះបានជំរុញមនុស្សឱ្យបែរទៅរក ***ភាវៈអធិធម្មជាតិ*** នេះ ដោយធ្វើការបួងសួង គោរពបូជាចំពោះព្រះអង្គ ហើយនិងរៀបចំធ្វើបុណ្យទាន (rites) ដើម្បីសុំការអនុគ្រោះប្រកបដោយ សេចក្តីសន្តោសប្រណី (benevolence) ពី ***ភាវៈសព្វានុភាព*** (all powerful Being) នេះ។ តើជំនឿសាសនាមានសក្តានុពលអ្វីខ្លះ ចំពោះជីវិតរស់នៅរបស់មនុស្ស?

## ៤. សក្តានុពលនៃជំនឿសាសនា

នៅក្នុងផ្នែកមុនៗ ដូចជានៅក្នុងផ្នែកនិយមន័យឬការចាប់ផ្តើមសាសនាដំបូងជាដើម សុទ្ធតែនិយាយទាក់ទងទៅនឹង សាសនា គឺក្នុងបំណងផ្តល់ឱ្យអ្នកអាននូវគំនិតអំពីសក្តានុពលដែលសាសនា បានបំពេញនៅក្នុងជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ និងសង្គមទាំងមូល។ នៅក្នុង ផ្នែកសក្តានុពលនៃជំនឿសាសនានេះ ខ្ញុំនឹងនិយាយជាពិសេសទៅលើសក្តានុពលនៃជំនឿសាសនាទូទៅដែលបានរៀបចំឡើង និងនៅតែដំណើរការដូចអ្នកប្រាជ្ញធ្លាប់បានយល់ដឹងនៅក្នុងវិស័យទស្សនវិជ្ជា និងសង្គមវិជ្ជាស្រាប់។ សក្តានុពលនៃជំនឿសាសនាទាំងនេះ បានបង្កើតឡើងប្រៀបដូចជាស្ថាប័នសង្គមនីមួយៗ ដូច្នេះដែរ ពោលគឺ សាសនាមានអត្ថិភាព និងសក្តានុពលភាពដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់មនុស្ស។

មានសេចក្តីពន្យល់មួយអំពីកំណើត និងការរីកចម្រើនរបស់សាសនានោះគឺ ***ឆន្ទៈ*** (will) ឬ ***តម្រូវការ*** (desire) រស់នៅរបស់មនុស្ស។ ជំនឿសាសនាគឺជា មធ្យោបាយមួយដែលតាមរយៈមធ្យោបាយនេះ ***មនុស្ស*** មានលទ្ធភាពអាចសម្របខ្លួនទៅនឹង ***ពិភពលោក ឬពិភពធម្មជាតិ*** ដែលពួកគេកំពុងរស់នៅជាមួយ ក៏ដូចជាចូលរួមរីករាយនឹងជីវិតពេញលេញ និងមានន័យខ្លឹមសារមួយដែរ។ ***កត្តាជីវសាស្ត្រ*** នេះ ក៏ជាចំណុចចាប់ផ្តើមល្អមួយនៅក្នុងការគិតពិចារណាពី ***សក្តានុពលនៃជំនឿសាសនា*** ផងដែរ។ ពីព្រោះ ថា រាល់សកម្មភាពរបស់មនុស្សម្នាក់ៗ ឬក្រុមសង្គម គឺត្រូវដឹកនាំឆ្ពោះទៅរកជំនួបមិនត្រឹមតែ ***តម្រូវការជីវសាស្ត្រ*** (the biological needs) ប៉ុណ្ណោះទេប៉ុន្តែ ***គ្រប់តម្រូវការ*** របស់មនុស្សទៀតផង។ ដូច្នេះ គ្មានអ្វីដែលត្រូវសង្ស័យទៀតទេថា សាសនាជាមធ្យោបាយដែលត្រូវសម្តែង ពីសក្តានុពលប្រែប្រួលជាច្រើនដើម្បីបំពេញនឹងតម្រូវការទាំងនេះ។

ជំនឿសាសនាមានសក្តានុពលសំខាន់ៗពីរយ៉ាង ពោលគឺ ***សក្តានុពល វិជ្ជមាន*** និង ***សក្តានុពលអវិជ្ជមាន***។

### ៤.១. សក្តានុពលវិជ្ជមាន

***សក្តានុពលវិជ្ជមាននៃជំនឿសាសនា*** ចង់និយាយពី ***អានុភាព ឬគុណភាព នៃជំនឿអរូបី*** (the unseen spirit), ***ជំនឿ ព្រេងកថា*** (legend), ***ជំនឿអធិធម្មជាតិ*** (supernatural

Being), **ជំនឿលើព្រះបង្កើត បំផ្លាញលោក** (Creator and Destroyer), **ឬជំនឿអច្ឆរិយជន** (supernatural Being) **របស់សាសនា** សុទ្ធសឹងតែជា **ជំនឿអរូបី** (unseen belief) ដែលមិនមានពិតនៅលើលោកនេះទេ ប៉ុន្តែជំនឿនេះមានសក្តានុពលដ៏ធំធេងអាចឱ្យអ្នកជឿប្រែក្លាយវាមកជា **តថភាពនៃជីវិតពិត** (the reality of real life) នៅលើផែនដីនេះបាន។ ករណីនេះ កើតមានពិតជាមួយនឹងប្រាសាទអង្គរវត្ត ដែលជាកំពូលស្ថាបត្យកម្មទេវកថាខ្មែរ (the supreme Khmer mythological architecture) នាសម័យបុរាណដ៏រុងរឿង។

ប្រាសាទអង្គរវត្តត្រូវបានគេកសាងឡើងសម្រាប់ថ្វាយព្រះបាទ **សូរ្យវរ្ម័នទី២** (Suryavarman II) នៅដើមសតវត្សទី១២ ដើម្បីឧទ្ទិសចំពោះព្រះវិស្ណុ[៨]។ មានអត្ថបទមួយសរសេរពីអង្គរវត្តថា "ពីរឿងព្រេងកថា មកជាជីវិតពិត (from legend become to real life)"។ ឃ្លានេះចង់បង្ហាញឱ្យឃើញពីគំនិតច្នៃប្រឌិតរបស់បុព្វបុរសខ្មែរពីជំនឿ សាសនាអរូបី ឬទេវកថា មកជារូបី ដែលជាតថភាពដើម្បីបម្រើដល់ការរស់នៅរបស់ប្រជាជនខ្មែរ។ រឿងនេះមិនថាតែប្រាសាទអង្គរវត្តនេះទេដែលមានលក្ខណៈបែបនេះ សូម្បីតែប្រាសាទបាយ័ន, ប្រាសាទ នាគព័ន្ធ...នៅក្នុងជំនឿពុទ្ធសាសនាមហាយានខ្មែរ, វត្ត (ព្រះវិហារ) ឬបល្ល័ង្កព្រះនៅក្នុងជំនឿពុទ្ធសាសនាថេរវាទតាំងពីក្រោយសម័យអង្គរ រហូតមកដល់សព្វថ្ងៃនេះក៏ដោយក៏មានលក្ខណៈទេវកថាដែរ។ ប្រាសាទបាយ័នជាប្រាសាទខ្មែរដ៏ល្បីល្បាញនិងតុបតែងដោយរឿងរ៉ាវជីវិតពិត និងតួអង្គសង្គ្រោះនៃអង្គពោធិសត្វលោកិតេស្វរៈយ៉ាងសម្បូរបែប។ ប្រាសាទនេះសាងសង់ឡើងនៅចុងស.វ.ទី១២ ឬដើមស.វ.ទី១៣ ជាប្រាសាទសំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧ ថ្វាយចំពោះព្រះពោធិសត្វ ដែលមានបដិមាព្រះអង្គ (ជ័យវរ្ម័នទី ៧) គឺជាតួអង្គតំណាង។ ចំពោះព្រះវិហារដែលជាទីតម្កល់ព្រះពុទ្ធរូបត្រូវបានគេកសាងឡើង ដោយទម្រ ឬខឿនចែកជា៣ថ្នាក់។ ថ្នាក់លើទី១ ដែលមានតម្កល់ព្រះពុទ្ធរូប គឺជា ឋានទេវលោក (ឋានលើ), ថ្នាក់បន្ទាប់ ទី២ ជាឋានមនុស្សលោក (ឋានកណ្តាល), ហើយនិងថ្នាក់ទី៣ជាទីអបាយភូមិ (ឋានក្រោម)។ នៅក្នុងជំនឿពុទ្ធសាសនាខ្មែរ ឋានទាំង៣នេះមានទំនាក់ទំនងជាមួយ គ្នា។ ឯបល្ល័ង្កព្រះមានសណ្ឋាន៣ថ្នាក់ ក៏បិតនៅក្នុងជំនឿនេះដែរ។

ប្រាសាទអង្គរវត្ត បើតាមជំនឿដែល គេនិយាយតៗគ្នាមកថា គឺជាក្រោលគោរបស់ព្រះឥន្ទ ដែលព្រះពិស្ណុការ (ព្រះវិស្សកម្មទេវបុត្រ) បានស្រឡាញ់ពេញចិត្ត ជាងប្រាសាទត្រៃត្រឹង្ស នានាផ្សេងទៀតរបស់ព្រះឥន្ទ ដើម្បីយកមកកសាងនៅលើផែនដីនេះ។ បើតាមការ

[៨]https://www.photodharma.net/Indonesia/26-Angkor Wat / index.htm

ស្រាវជ្រាវរបស់ ហ្ស. សឺដែស (G. Coedes) លោកមានមតិថា ប្លង់ប្រាសាទអង្គរដែលមាន **កំពែង, គូទឹក, ប្រាង្គកណ្ដាល** និង **ទ្វារប្រាសាទ** ជា ពីរ៉ាមីត **ស្ពានបង្កាន់ដៃនាគ**... គឺគ្មានអ្វីក្រៅពីការបកស្រាយអំពី **ទេវកថានៃលោកធាតុវិទ្យាហិណ្ឌូ** មកជារូបភាពជាក់ស្ដែង អំពីថ្មនៅលើភពផែនដីយើងឡើយ។



ប្លង់ប្រាសាទអង្គរតូច ប្រទេសកម្ពុជា
ប្រភព៖https://www.photodharma.net/Indonesia /26-Angkor Wat / index.htm

នៅក្នុងជំនឿព្រហ្មញ្ញសាសនា គេប្រើ **បញ្ញត្តិកម្ម** អំពីពិភពលោកថាទ្វីបធំមួយហៅថា **ជម្ពូទ្វីប** ដែលនៅចំកណ្ដាល មាន **ភ្នំព្រះសុមេរុ** ព័ទ្ធដោយពិភពតាភា។ **ជម្ពូទ្វីបមានទ្វីប៦** និង **មហាសមុទ្រ៧** ព័ទ្ធជុំវិញដែលមាន**មហាកំពែង** **ថ្មជាព្រំដែន**។ នៅលើ **កំពូលភ្នំព្រះសុមេរុ** ជា **ស្ថានរបស់ព្រះព្រហ្ម** គឺជា **ស្ថានទេវលោក** ដែលមានទិសទាំង៨ជាឆ្មាំការពារ។

ជាការពិតណាស់ ដែលអ្នកនគរូបនីយកម្មហិណ្ឌូ និងកម្ពុជាមិនបានស្ថាបនា ឱ្យបានសព្វគ្រប់ដូចក្នុងទេវកថា។ **ប្រាសាទ** តាំងនៅកណ្ដាលទីក្រុង គឺជា **ភ្នំមេរុ, ជញ្ជាំងកំពែងព័ទ្ធជុំវិញ** ទុកដូចជាជញ្ជាំងសិលាព័ទ្ធជុំវិញសកលលោក និង **គូទឹក** ទុកដូចជាមហាសាគរ។ ការនិយាយបែបនេះ ពុំមែនជាលទ្ធផលនៃមនោគតិដ៏ហួសហេតុនោះទេ តែនេះគឺជាគំនិតដែលមាននៅក្នុង **អក្សរសិល្ប៍** ដែលកវីហិណ្ឌូបាន និពន្ធឡើងដូចជាអ្នកប្រាជ្ញអក្សរសាស្ត្រ ខ្មែរបានចារសិលាចារឹកនៅប្រាសាទនានា ក្នុងប្រទេសកម្ពុជាសម័យបុរាណ[៦]។

តាមជំនឿ និងការចង្អុលបង្ហាញរបស់លោក សឺដែស ពីបញ្ញត្តិកម្មខាងលើ អង្គរវត្តមិនមែនជាប្រាសាទនៅលើផែនដីនេះទេ តែជាប្រាសាទសួគ៌នៅឋានព្រះ ឥន្ទ។ តាមលំអាននេះដែរ បើយើងសង្កេត មើលប្រាសាទនេះនៅក្នុងមនោគតិដ៏ជ្រាលជម្រៅ នោះគេនឹងរកឃើញពីទិដ្ឋភាពពិតប្រាកដថា ផ្លូវចាក់កៅស៊ូពីត្បូង ទៅជើងឆ្ពោះទៅប្រាសាទបាយ័នជាផ្លូវ ដែលនៅជាប់នឹងជណ្ដើរបង្កាន់ដៃនាគឡើងចូលទៅក្នុងប្រាសាទអង្គរវត្តខាងលិច គឺជាឋានមនុស្ស (ឋានកណ្ដាល ឯឋានក្រោមបាត់រូបភាព តែបើគេសញ្ជឹង គិត គេនឹងរកឃើញ)។ ពេលគេជាន់ជើង លើជណ្ដើរបង្កាន់ដៃនាគខាងលិច មួយ ពីរ បី... ចូលទៅក្នុងប្រាសាទ មានន័យថា គេកំពុងធ្វើដំណើរឡើង

---

៦ ហ្ស. សឺដែល (ប្រែ ម៉ុញ សារី) *«ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ»*, ប៉ារីស, ១៩៤៧, ទំព័រ ៥៣

ទៅឋានសួគ៌ (សូមមើលរូប)។ ពេលគេចូលនិង ឡើងទៅដល់ប្រាង្គធំកណ្តាល មានន័យថា គេកំពុងនៅជាមួយអាទិទេពអង្គព្រះវិស្ណុនៅឋានសួគ៌ ដែលមានព្រះបាទ **សូរ្យវរ្ម័នទី២** ជាតំណាងនៅទីនោះ។

ទិដ្ឋភាពនេះមិនខុសអីពីទិដ្ឋភាពជណ្តើរមាសប្រាក់និងកែវ ឬនៅក្នុងអត្ថបទខ្លះថាជាជណ្តើរ៧ពណ៌ដែលជារូបគំនូរព្រះពុទ្ធសាសនាសម័យទំនើបដែល បង្ហាញអំពីព្រះពុទ្ធយាងចុះពីស្ថានត្រៃ ត្រឹង្ស បន្ទាប់ពីបានទេសនាប្រោសពុទ្ធ មាតាតាមជណ្តើរមាសប្រាក់ និងកែវនេះ នោះឡើយ។

### ៤.២. សទ្ធានុពលអវិជ្ជមាន

ផ្ទុយទៅនឹង **សក្តានុពលវិជ្ជមាននៃជំនឿសាសនា** ខាងលើ **សក្តានុពលអវិជ្ជមាននៃជំនឿសាសនា** ចង់សំដៅជាសំខាន់ ទៅលើ **លទ្ធភាពនៃជំនឿអរូបី ឬជំនឿអធិ ធម្មជាតិ** ដែលមិនមាន **សច្ចភាព**(truth) ឬ**តថភាព**(reality) ហើយដែលអាចបង្ក ឬ ជំរុញអ្នកជឿឱ្យជឿថា **មានអពិត**។ ជំនឿបែបនេះគេហៅថា **ជំនឿគ្មានផល** (faith without result) គឺមានតែហេតុផ្តើមពោលគឺ មានតែជំនឿតែអត់ដែលឃើញឱ្យផលពីជំនឿនោះវិញទេ។ ជំនឿបែបនេះមានលក្ខណៈអសកម្ម បើអ្នកណាម្នាក់ហ៊ានទទួលអ្នកនោះនឹងត្រូវចំណាយទ្រព្យធន ឬពេលខ្លះអាចប៉ះពាល់ដល់អាយុជីវិតទៀតផង។ ឧទាហរណ៍ នៅក្នុង ពិភពលោកព្រះដែលមានឬទ្ធិមានមកពី គ្រប់សាសនា តែសង្គ្រាមលោកលើកទី១ ទី២ ហើយសព្វថ្ងៃសង្គ្រាមដែលរុស្សីបង្កឡើងនៅអ៊ុយក្រែន សង្គ្រាមនៅកូមាសង្គ្រាមថៃឈ្លានពានខ្មែរ និងគ្រោះរញ្ជួយស៊ូណាមិ នៅតែកើតមានជាហូរហែរ អត់ដែលឃើញព្រះមកពីសាសនាណាមួយអាចបញ្ឈប់បាន។ តើព្រះមានពិតមែនដែរឬអត់? ជំនឿប្រភេទនេះកើតចេញមកពីរវាងមនុស្សពីរពួក គឺ **បញ្ញាជន** (intellectual) និង**អវិជ្ជាជន** (ignorant man)។

**បញ្ញាជន** នៅទីនេះចង់និយាយសំដៅទៅដល់ជនទាំងឡាយដែលមាន **បទពិសោធន៍** ឬ**ពុទ្ធិច្រើន** សព្វយ៉ាងជាពិសេសចេះដឹងច្រើនក្នុងរឿងសាសនា រហូតដល់អាចឱ្យគេហៅបានថាជា **សព្វបញ្ញជន** (scholars) ក៏បាន ហើយយក **បទ ពិសោធន៍** ឬ **ពុទ្ធិ** ដែលពួកគេចេះដឹងច្រើននេះទៅប្រើខុសក្នុងគោលបំណង បំភាន់អ្នកជឿឱ្យយល់ខុស ជឿខុស និង ប្រតិបត្តិខុសដើម្បីទាញយកប្រយោជន៍ អ្វីមួយពីពួកគេ។ និយាយឱ្យចំក្នុងន័យ នេះ គឺចង់សំដៅចំពោះ **បញ្ញាជនទាំងឡាយ** ដែលដូចភាសាក្រិចបុរាណហៅថា **ពួកសូហ្វីស** ឬ **សូហ្វីសវិទូ** នេះឯង។

**សូហ្វីសវិទូ** (Sophists) ន័យដើម របស់ពាក្យនេះគឺ **អ្នកប្រាជ្ញ**, **អ្នកមានបទ ពិសោធន៍**, **អ្នករកឃើញ**។ ប៉ុន្តែ ចាប់ពីពាក់កណ្តាលក្រោយ **ស.វ.ទី៥មុនគ.ស** ពាក្យនេះបានក្លាយទៅជាឈ្មោះសម្រាប់ហៅ **ទស្សនវិទូពិសេស**។ ពោល

គឺ ទស្សនវិទូដែលមានឯក**ទេសខាងការស្រាវជ្រាវ, ខាងសិល្បៈវោហារ, ខាងសិល្បៈពិភាក្សាវែកញែក,** និង**ខាងសិល្បៈគូសបញ្ជាក់ឱ្យបានច្បាស់លាស់។** សូហ្វីសមួយចំនួនជា **អ្នក វិជ្ជាសមោធាន** (encyclopedist) ដូចជា **ហ៊ីពីយ៉ាស** (Hippias) បង្រៀនពិជគណិត, ធរណីមាត្រ, តន្ត្រី, តារាវិទ្យា, បច្ចេកទេស, បុរាណវត្ថុវិទ្យា, និងបង្រៀនពីវណ្ណកម្ម នៃអ្នកករីហូម៉ែរ។ **អង់ទីហ្វុង** បង្រៀនរូបវិទ្យា និងវិធីរកផ្ទៃក្រឡាមណ្ឌល។ **ប្រូឌី គូស** បង្រៀនរូបវិទ្យានិងសីលវិជ្ជា។ ប៉ុន្តែ នៅសម័យក្រោយមក ពាក្យនេះបានក្លាយទៅជា **ពាក្យថ្នុកកម្ទេង** ដែលត្រូវគេមើស្រាលទៅវិញ ដោយសារតែពួកគេ ជាពួកបោកបន្ទំខ្វះមនសិការ ពឹងផ្អែកទៅលើផលប្រយោជន៍។ ដោយហេតុនេះ ហើយបានជាមកដល់ពាក់កណ្ដាលដើម ស.វ.ទី **៤មុន គ.ស សូហ្វីសវិទូមួយចំនួនធំ** បានក្លាយជា **គ្រូមន្តអាគមន៍ខាងភាសា** និងក្លាយជា **អ្នកនិយាយបំភាន់ការពិត** ធ្វើឱ្យពាក្យ **សូហ្វីស** ក្លាយជាពាក្យមួយដែលគួរមើលងាយនោះ[១០]។ ឧទាហរណ៍អំពីការបំភាន់សច្ចភាពរបស់ហ្សេណូ (Zeno) ជា សូហ្វីសវិទូក្រិក លោកនិយាយថា ព្រួញ ដែលគេបាញ់ទៅ ត្រូវឈប់ជាបន្តបន្ទាប់ នៅលើចំណុចនីមួយៗលើទីតាំងនីមួយៗ នៅលើផ្លូវហោះទៅរកគោលដៅ។ ហេតុនេះ ទោះបីវាហោះក្នុងរយៈពេលខ្លីក៏ដោយ ក៏វាបានឈប់ស្ងៀមនៅលើចំណុចនីមួយៗនៃផ្លូវនេះដែរ។ ផលបូកនៃជំហាប់ស្ងៀម គឺជាជំហាប់ស្ងៀម។ ហេតុនេះ ព្រួញដែលកំពុងហោះគឺជា[១១]ព្រួញដែលឈប់ស្ងៀម។ បើអញ្ចឹងភាវៈជាភាវៈឥតចលនា។ តាមពិតព្រួញដែលផ្លាស់ពីទីតាំងមួយទៅទីតាំងមួយ គឺជាចលនារបស់ព្រួញ នេះជារបៀបនិយាយបំភាន់សច្ចភាពរបស់ពួកសូហ្វីស។



គន្ទូសបព្រួញអពព្រួញ
អចលនារបស់ហ្សេណូ

ចំពោះ **អវិជ្ជាជន** វិញ គឺចង់សំដៅដល់ជនទាំងឡាយដែលមាន **បទពិសោធន៍ តិច** ដែលភាគច្រើនពុទ្ធិរបស់ពួកគេកើត ចេញមកពី **ឥន្ទ្រិយ** (senses) ច្រើនជាងខួរក្បាល ដែលធ្វើឱ្យពួកគេងាយយល់ ងាយជឿ និងងាយធ្វើតាមដែលនាំឱ្យ**បញ្ញាជនខាងលើ** ងាយពន្យល់, ងាយ បញ្ចុះបញ្ចូល, ងាយបោក និងងាយអូសទាញឱ្យជឿនិងដើរតាម។ ឧទាហរណ៍ ស្ដេចសៀមក្រោយពីបានតាំងរាជធានី នៅក្រុង **អយុធ្យា** ហើយក៏បានលើកទ័ព ចូលមកវាយខ្មែរ។ តែមុននឹងមកដល់អង្គរ ទ័ពសៀមត្រូវឧបរាជខ្មែរ

[១០]ឆយ យើហ៊ាង, ជ.ឯ.ម, ទំព័រ ៤៥-៤៦

[១១]-ដ-, ទំព័រ ២៣

(សុរយោទ័យ អនុជលំពង់រាជា) លើកទ័ពទៅស្កាត់វាយ បាក់ទ័ពថយទៅវិញអស់។ ព្រះលំពង់រាជានឹកស្មានថាសត្រូវពុំអាចធ្វើអ្វីបានទៀត (បទពិសោធន៍ឥន្ទ្រិយ) ក៏ទ្រង់បញ្ជារំសាយកងទ័ពឱ្យទៅកាន់ទីលំនៅរៀងៗខ្លួនវិញ។ លុះឮថាសៀមលើកទ័ពចូលមកជាថ្មីម្ដងទៀត ខ្មែរកែនទ័ពមិនទាន់ក៏ ដេញរាស្ត្រឱ្យចូលក្នុងកំពែងមហានគរ ហើយកែនពលឱ្យការពារ។ ទ័ពសៀមមកលោមព័ទ្ធជុំជិត អស់រយៈពេល១ឆ្នាំ៥ខែ។ ទ័ពជំនួយខ្មែរជាច្រើនបានលើកពីកន្លែង ផ្សេងៗ តែដោយមកមិនស្មើគ្នាក៏ត្រូវទទួលបរាជ័យ។ រាជធានីអង្គរត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃរសៀមនៅឆ្នាំ ១៣៥២[12]។ ចាញ់កលសៀមម្ដងទៀត នៅពេលស្ដេច **រាមា សូរ** បានឡើងសោយរាជ្យ ស្ដេចនេះបានលើកទ័ពមកឡោមព័ទ្ធក្រុងអង្គរសាជាថ្មី អស់រយៈពេល៧ខែ (ពីខែមិគសិរដល់ខែ ជេស្ឋ)។ ដោយឃើញថា មិនអាចប្រយុទ្ធយកជ័យជំនះលើខ្មែរដោយកម្លាំងអាវុធ បាន ទើបសៀមប្រើឧបាយកល ដោយឱ្យទាហានសៀមចំនួន១៥នាក់ ធ្វើកលសុំចុះចូលខាងខ្មែរ ដោយយកលេសថា ស្ដេចសៀមធ្វើបាបខ្លួនខ្លាំងពេក ព្រោះតែ ខ្លួនច្បាំងមិនឈ្នះខ្មែរ។ នៅទីបំផុតពួកនេះ បានរកមធ្យោបាយបើកទ្វារខាងលិចបាន។ ក្រុងអង្គរក៏ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃសៀមជាលើកទី២ (១៣៩៣) (សញ្ចេតនា ខ្វះបញ្ញា)[13]។ បើតាមប្រវត្តិសាស្ត្រនៅក្នុង ការធ្វើសឹកសង្គ្រាម បើគិតពីកម្លាំងប្រយុទ្ធ ទ័ពខ្មែរមិនដែលខ្សោយជាងសត្រូវនោះទេ។ ទ័ពខ្មែរតែងតែមានជោគជ័យជាដរាប។ ប៉ុន្តែ ពួកគេចាញ់សត្រូវច្រើនតែចាញ់នៅត្រង់សត្រូវប្រើកលល្បិចនៅក្នុងសញ្ចេតនាស្មោះត្រង់ក្លែងក្លាយនេះឯង។ នៅក្នុងសឹកសង្គ្រាមក្ដី នៅក្នុងនយោបាយដឹកនាំប្រទេសក្ដី ឬនៅក្នុងមុខជំនួញរក ស៊ីក្ដី **ល្បិចកល** គឺជា **កម្លាំងស្ទួល** ដែលខ្លាំងជាងកម្លាំងបាយ (កម្លាំងកាយ) ពីព្រោះវាមានប្រភពមកពី **ខួរក្បាល** មិនមែនមកពី **ឥន្ទ្រិយ** នោះឡើយ។ អ្នកដែលជឿលើ **ឥន្ទ្រិយ** ងាយគ្រោះថ្នាក់បំផុតពីព្រោះ ងាយជឿ និងងាយប្រគល់សេចក្ដីទុកចិត្តទៅឱ្យគេ។ ឧទាហរណ៍ បន្ទាយលង្វែកត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃសៀមនៅឆ្នាំ១៥៩៣ ដោយចាញ់ឧបាយកលសៀមដែលបាញ់ប្រាក់ដួងចូលទៅ ក្នុងគុម្ពឫស្សីដែលជារបងការពារដ៏រឹងមាំ ហើយម្យ៉ាងទៀត សៀមបានចាត់ចារបុរសពីរនាក់ចូលមកធ្វើវិទ្ធង្សនាបង្កើតឱ្យមានចលាចលក្នុងផ្ទៃក្នុងរបស់ខ្មែរ មហាតលិកសៀមពីរនាក់បានក្លែងធ្វើជាអ្នកបួសនាម **តិបញ្ញោ** និង **សុប្បញ្ញោ** ចូល មកធ្វើពិធីដកសិល្ប៍សាស្ត្រដែលបញ្ចុះ ក្នុងរូបទេវ

[12] ត្រឹង ងា, "*ប្រវត្តិសាស្ត្រខ្មែរ ភាគ១និង២ (សម្រាប់មធ្យម និងឧត្តមសិក្សា)*," ភ្នំពេញ, ព.ស. ២៥១៧, គ.ស. ១៩៧៣, ទំព័រ ១០៦

[13] -ដ-, ទំព័រ ១០៧

វក្សៗ **សុប្បញ្ញោ** ប្រើមន្តអាគម ធ្វើឱ្យអ្នកស្រុក ឈើ **តិបញ្ញោ** ជាអ្នកដោះឱ្យ ជាសះ ស្បើយឡើងវិញ[១៤]ៗ

សង្គ្រាមរវាង **ស្រីសុគន្ធបទ** និង **ស្ដេចកន** កើតចេញមកពី ព្រះបាទ ស្រីសុគន្ធបទ ជឿតាមការទស្សទាយរបស់ហោរាដែលទស្សទាយពីការសុបិនឃើញ នាគរាជដេញខាំព្រះអង្គ ហើយខាំពាំ ស្វេតច្ឆ័ត្ររបស់ព្រះអង្គទៀតនោះថា មាន កោលាហលចំពោះព្រះអង្គ ហើយអ្នកបង្ក គឺ ឃុនហ្លួងព្រះស្ដេចកន ដែលកើតនៅឆ្នាំរោង (នាគ) ហើយស្របពេលជាមួយគ្នានោះមានពាក្យបណ្ដឹងមកថា មានកើត ហេតុចម្លែកផ្សេងៗនៅក្នុងព្រះរាជាណាចក្រ ហើយម្យ៉ាងវិញទៀត ដោយខ្លាច ក្រែងស្ដេចកនក្បត់ដណ្ដើមរាជសម្បត្តិ សមដូចទំនាយរបស់ហោរាផងនោះ ព្រះបាទស្រីសុគន្ធបទទ្រង់បានធ្វើការប្រជុំសម្ងាត់នៃពួកមន្ត្រីជំនិត ដើម្បីរិះរកមធ្យោបាយកំចាត់ស្ដេចកនឱ្យបានៗ គំនិតនេះ បានបង្កឱ្យកើតសង្គ្រាមតាមសម្ងាប់គ្នា រហូតដល់ចុងក្រោយ ព្រះបាទស្រីសុគន្ធ បទ ត្រូវមន្ត្រីម្នាក់ឈ្មោះ ឱកម៉ឺនសុរិន្ទកែវ និងបក្សពួកបះឡើង ចូលចោមធ្វើគត់ព្រះ អង្គបានក្នុងបន្ទាយស្ទឹងសែននៅ គ.ស. ១៥១២[១៥]ៗ

**អវិជ្ជាជន** ដែលយក **ឥន្ទ្រិយ** មកធ្វើជាមូលដ្ឋានទុកចិត្តរឹងមាំសម្រាបសេចក្ដីសុខសេចក្ដីចម្រើននៅក្នុងជីវិត គឺមិនអាចទៅរួចឡើយ ទីបំផុតពួកគេត្រូវតែ វិលទៅរក **កម្លាំងវិចារណញ្ញាណ** (reaso-ning power) វិញទើបបានៗ នៅក្នុង **លទ្ធិ សនិទាននិយម** (rationalism) យល់ថា គេអាចសម្រេច **ពុទ្ធិសច្ច** បានតាមរយៈ **ការគិតពិចារណា** (reasoning) ច្រើនជាងតាមរយៈ **បទពិសោធន៍ឥន្ទ្រិយ** (sensory experience)ៗ **អ្នកសនិទាននិយម** (ratio-nalists) អះអាងថា **ស្មារតី** (mind) មានកម្លាំងអាចយល់ដឹងបានពី **សច្ចភាព** (the truth) ដោយខ្លួនវាតាមរយៈការប្រើ **ទម្រង់ការពិចារណាជាក់លាក់** តែមួយប៉ុណ្ណោះៗ **ទម្រង់ការសនិទាននិយម** ធ្វើឱ្យមនុស្ស មានលទ្ធភាពអាចទទួលបាននូវ **ពុទ្ធិខ្ពង់ ខ្ពស់បំផុតមួយ** ដែលស្ថិតនៅក្នុងកាលៈទេសៈណាក៏មិនចេះខុសៗ ឧទាហរណ៍ នៅក្នុងពុទ្ធសាសនាណែនាំពុទ្ធបរិស័ទឱ្យ ជឿថា **ធម្មទាន** [Dharma Dana (អំណោយ ពុទ្ធិ)] ល្អប្រសើរជាង **អាមិសទាន** [Amisa Dana (អំណោយសម្ភារៈ)]ៗ ត្រូវនឹងសុភាសិតខ្មែរថា "បង្រៀនឱ្យចេះស្ទូចត្រីប្រសើរ ជាជាងឱ្យត្រី"ៗ ដូចគ្នានេះដែរ ឪពុកម្ដាយ ជនជាតិខ្មែរយល់ថា ការចែកទ្រព្យបញ្ញា ឱ្យកូនល្អប្រសើរជាងឱ្យទ្រព្យសម្ភារៈៗ ពួកគាត់យល់ថា បញ្ញាចាយច្រើនចម្រើនច្រើន ហើយចោរលួចមិនបានទៀតផងៗ **ទម្រង់ការសនិទាននិយម** អះអាងយ៉ាងមុតមាំថា **បទពិសោធន៍ឥន្ទ្រិយ** មិនអាចនាំមកឱ្យមនុស្សនូវ **ពុទ្ធិត្រឹមត្រូវជាច់ខាត**

---

[១៤] -ដ-, ទំព័រ ១៥៤-១៥៦

[១៥] -ដ-, ទំព័រ ១៤០

ទៅតាមវិធីណាមួយនោះបានទេ។ នៅទី បំផុត មនុស្សត្រូវតែវិលទៅរក **កម្លាំងពិចារណា** (reasoning faculty) របស់គេវិញដោយខានមិនបាន[១៦]។

សរុបសេចក្តីមក សក្តានុពលនៃ ជំនឿសាសនាមានអានុភាពខ្លាំង មិនថា ផ្លូវវិជ្ជមាន ឬអវិជ្ជមាន។ អានុភាពខ្លាំងទៅ តាមផ្លូវណាមួយវិជ្ជមាន ឬអវិជ្ជមាន គឺវា អនុលោមទៅតាមសមត្ថភាព ឬទេពកោសល្យរបស់អ្នកជឿរបស់វា។ ឧទាហរណ៍ បុព្វបុរសខ្មែរបានកសាងសម័យអង្គរដ៏រុងរឿង ដែលធ្វើឱ្យអរិយធម៌ខ្មែរសម័យនោះ មានវិបុលភាពឡើងដល់កំពូល ហើយដែលបានបន្សល់ទុកជាកេរមត៌កមកឱ្យកូនខ្មែររហូតមកដល់សព្វថ្ងៃនេះ ដោយ ពួកគាត់ប្រកាន់យកតាមជំនឿវិជ្ជមាន ពីជំនឿព្រេងកថាមកជាជីវិតពិត។ នេះជា គំរូគំនិតល្អដែលកូនចៅជំនាន់នេះ ឬ ជំនាន់តៗទៅទៀត ត្រូវរៀនសូត្រតាម។

## សេចក្តីសន្និដ្ឋាន

ឈរលើ **គំនិត** ឬ **ទស្សនៈតថនិយម** (realism) នៅក្នុងជំនឿសាសនារបស់ដូន តាខ្មែរ ពួកគាត់បានកសាងប្រទេសមួយ ដែលសម្បូររុងរឿង និងមានវិសាលភាព ទឹកដូជំទូលាយ នៅក្នុងអាស៊ីអាគ្នេយ៍នេះ។ ភាពសម្បូររុងរឿង និងមានទឹកដីធំទូលំទូលាយនេះ មិនមែនកើតឡើងដោយចៃដន្យ, ដោយអាទិទេព, ឬដោយអ្នកមានបុណ្យអង្គណាមួយមកជប់ ឬនិមិតនោះ ឡើយ ប្ចីត្បិតតែពួកគាត់ផ្តេកផ្តួលទៅលើជំនឿសាសនាខ្លាំងក្លាក៏ដោយ គឺកើតឡើងដោយ **មនុស្សទេពខ្មែរ** (Khmer divine people) នេះឯង។ សមិទ្ធិផលទាំងឡាយដែលបានកើតឡើងយ៉ាងប្រចក្សនៅលើទឹកដីខ្មែរមកដល់សព្វថ្ងៃនេះ គឺកើតឡើងចេញមកពីគំនិតច្នៃប្រឌិត នៅក្នុងហេតុផលថា ជឿសាសនាមិនមែន ដើម្បីតែបុព្វហេតុជំនឿសាសនានោះប៉ុណ្ណោះទេ ប៉ុន្តែ ដើម្បីការរស់នៅជាក់ស្តែងនៅលើផែនដីនេះដោយពិតៗ។ បើ ជំនឿដើម្បីតែជំនឿ គឺវាគ្មានប្រយោជន៍អ្វីដល់មនុស្សសញ្ជាតិ ជាពិសេសសម្រាប់មនុស្សខ្មែរនេះឡើយ។ ប្រាសាទអង្គរវត្ត, បារាយណ៍, ទឹកដីធំទូលាយក៏មិនបានកើតឡើងនៅលើទឹកដីនេះដែរ។ ព្រះបាទ ជ័យវរ្ម័នទី២ ជឿជាក់លើមហិទ្ធិឫទ្ធិព្រះ ឥសូរបានប្រែក្លាយព្រះអង្គឯងឱ្យទៅជាស្តេចអាទិទេពដែលមានជីវិតនៅលើផែនដី ដើម្បីដឹកនាំបង្រួបបង្រួមជាតិ និង ចាប់ផ្តើមសម័យអង្គរដ៏រុងរឿង, ព្រះបាទសូរ្យ វរ្ម័នទី២ ជឿជាក់លើបារមីព្រះវិស្ណុមានឫទ្ធិចេស្តា ក្លាហានក្នុងសឹកសង្គ្រាម ត្រូវបានអ្នកស្រាវជ្រាវ ឱ្យព្រះនាមថាជាស្តេចសឹកខាង ពង្រីកទឹកដីមានស្នាព្រហស្ត កសាងប្រាសាទ អង្គដ៏ល្អគ្មានពីរលើលោក។ ឯព្រះបាទជ័យវរ្ម័នទី៧ ក៏មានទេពកោសល្យមិនចាញ់ស្តេច ទាំងពីរអង្គខាងលើនេះដែរ។ ស្ថិតនៅក្នុងឥទ្ធិពលមនោគមន៍

[១៦] Venancio B. Ardales, op. cit. p.57

*នៃជំនឿពុទ្ធសាសនាមហាយាន ព្រះអង្គបានកសាងប្រាសាទអង្គធំដែល មានប្ចង់ស្មុគស្មាញ និងប្រកបទៅដោយព្រះភក្ត្រព្រះពោធិសត្វ លោកិតេស្វរៈ ដើម្បីចាំជួយស្រោចស្រង់ប្រជាជនខ្មែរ ដែលវង្វេងខ្លួននៅក្នុងវាលវដ្តសង្សារ ដោយសារតែមានអវិជ្ជាជ្រៅៗ គំនិតប្រែក្លាយជំនឿសាសនា អរូបីមកជារូបីដើម្បីបុព្វហេតុនៃជីវិតរស់នៅៗនៅលើផែនដីនេះ គឺជាទេពកោសល្យឯករបស់បុព្វបុរសខ្មែរប្រសើរខ្ពង់ខ្ពស់ជាងជាតិអត់កំណើតខ្វះដែលចាំតែលួចប្ចន់ទឹកដី និងសម្បត្តិវប្បធម៌របស់គេៗ*

## គន្ថនិទ្ទេស


### I- ស្នាដៃនិពន្ធជាភាសាខ្មែរ

១- ឆយ យីហ៊ាង, "*ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក*",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤

២- ជួន ណាត *វចនានុក្រមខ្មែរអេឡិចត្រូនិច*, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ២០០៨

៣- ត្រឹង ង៉ា "*ប្រវត្តិសាស្រ្តខ្មែរ ភាគ១និង ២ (សម្រាប់មធ្យម និងឧត្តមសិក្សា)*"ភ្នំពេញ, ព.ស. ២៥១៧, គ.ស. ១៩៧៣

៤- ហ្សូ. សឺដែស (ប្រែ ម៉ុញសារី) «*ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ*» ប៉ារីស ១៩៤៧

### II- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

1- *Jonathan* Crowther, *Oxford Advanced Learner's Dictionary of Current English,* Oxford University Press, Oxford New York, 5th Ed, 1995

2- Cambridge Advanced Learner's Dictionary, 3rd ed. p faith

3- Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974

4- https://www.photodharma.net/Indonesia/26-Angkor Wat / index.htm